ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន
លេខ: 13 ស.ក.អ/៩៧

ភ្នំពេញ, ថ្ងៃទី២៤ ខែ [illegible] ឆ្នាំ១៩៩៧

# សេចក្តីជូនដំណឹង
## ស្តីពី
## សៀវភៅការងាររបស់និយោជិត-កម្មករខ្មែរ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជំរាបជូនដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវា កសិកម្ម ទាំងអស់ដែលមានចែងនៅក្នុងមាត្រា ១ នៅក្នុងច្បាប់ការងារបានជ្រាបថា យោងតាមមាត្រាលេខ ៣២ នៃច្បាប់ការងារ និយោជិត-កម្មករសញ្ជាតិខ្មែរ ដែលបំរើការងារនៅក្នុងរោងចក្រ សហគ្រាសរបស់ឯកជន ត្រូវតែមានសៀវភៅការងារដែលចេញ ដោយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

ចំពោះអ្នកនៅរាជធានីភ្នំពេញ សូមអញ្ជើញទៅធ្វើសៀវភៅការងារ នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ស្ថិតនៅអគារលេខ ៦៨ ផ្លូវ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ចំពោះអ្នកនៅតាមខេត្ត-ក្រុងនានា សូមអញ្ជើញទៅធ្វើសៀវភៅការងារនៅគ្រប់អធិការដ្ឋានខេត្ត-ក្រុងរៀងៗខ្លួន ។

សុំណុំលិខិតដែលត្រូវបំពេញមានដូចតទៅ :

| | |
|---|---|
| ១. ពាក្យសុំធ្វើសៀវភៅការងារបិទតែមប្រី ១.០០០៛ | ០១ ច្បាប់ |
| ២. អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ទីលំនៅ | ០១ ច្បាប់ |
| ៣. លិខិតបញ្ជាក់ពីមុខរបរចេញ ដោយនិយោជក | ០១ ច្បាប់ |
| ៤. អាករចំនួន | ១ ៥០០ រៀល |
| ៥. រូបថត ៤ x ៦ ស.ម | ០៤ សន្លឹក |

អាស្រ័យហេតុនេះ សូមនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងអស់រៀបចំកម្មវិធីដើម្បីបង្កលក្ខណៈងាយស្រួលអោយនិយោជិត-កម្មករក្រោមឱវាទ ទៅធ្វើសៀវភៅ ការងារអោយបានគ្រប់ៗគ្នា ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន រោងចក្រ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះអោយបានទៀងទាត់ និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខាន ។ល។

<u>ចម្លងជូន</u>

. ទីស្តីការគណៈរដ្ឋមន្ត្រី

. អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

. ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

. ក្រសួងមហាផ្ទៃ

. ក្រសួងយុត្តិធម៌

. ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

. ក្រសួងព័ត៌មាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"

. គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុង "ដើម្បីអនុវត្ត"

. បិទផ្សាយ

. កាលប្បវត្តិ និងឯកសារ

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន

ស៊ុយ សែម